**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

**សភាស៊ើបសួរ**

សំណុំរឿងស៊ើបសួរលេខ: ១៣

ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

**សាលដីកា**

លេខ: **១៩** ស.ស ក្រ.IV ( ខ.ណ )

ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

បានបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យ ប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤០/០១៥ ចុះថ្ងៃទី ១៦/០៧/២០១៤ បានបើកសវនាការជាអសាធារណៈ នៅសាលសវនាការនៃ សាលាឧទ្ធរណ៍ត្បូងឃ្មុំ នាព្រឹកថ្ងៃចន្ទ ៧ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹង ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ដែលមានសមាសភាព ដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

**<u>ជនត្រូវចោទ:</u>**

១-ឈ្មោះ [redacted] ប៊ុនថា ហៅ ឌី ភេទប្រុស អាយុ ១៦ឆ្នាំ ជានីតិជន ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ថ្នាក់ទី០២ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តត្បូងឃ្មុំ ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ស្ថានភាពគ្រួសារ នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន គ្មាន ។ (ក្នុងឃុំ) (**ម្ចាស់បណ្តឹងឧទ្ធរណ៍**)

-លោក [redacted] រ៉ាពិសិដ្ឋ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ។

-ដីកាបង្គាប់ឱ្យឃុំខ្លួន លេខ ៥៨៩ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: លួច ប្រព្រឹត្តនៅចំណុចភូមិ៤៤ ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិន ភេទប្រុស អាយុ ៦៣ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តត្បូងឃ្មុំ។

## ១-អំពីអង្គហេតុនៃការចោទប្រកាន់

កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង១៨ និង០០នាទី នៅចំណុចភូមិ៤៤ ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ជនសង្ស័យឈ្មោះ [redacted] ប៊ុនថា ភេទប្រុស អាយុ១៦ឆ្នាំ បានធ្វើសកម្មភាពចូលក្នុងផ្ទះជនរងគ្រោះឈ្មោះ [redacted] ម៉ារ៉ាក ភេទស្រី អាយុ ៤២ឆ្នាំ និងប្ដីឈ្មោះ [redacted] សារិន ភេទប្រុស អាយុ ៦៣ឆ្នាំ លួចយកទូរស័ព្ទម៉ាក Iphone 6plus ប្រាក់ចំនួន ១,០០០,០០០ (មួយលាន) រៀល។ ក្រោយពីសមត្ថកិច្ចទទួលបានពត៌មាននេះ ដែលទូរសព្ទដែលបានបាត់មានភ្ជាប់ Icloud និងប្រើប្រាស់មុខងារ fine iphone កម្លាំងសមត្ថកិច្ចក៏បានធ្វើការស្រាវជ្រាវរកតាម GPS ក៏បានជួបជនសង្ស័យឈ្មោះ [redacted] ប៊ុនថា និងឆែកឆេរឃើញទូរស័ព្ទ Iphone 6plus សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនបានជនសង្ស័យបញ្ជូនមកកាន់អធិការដ្ឋាននគរបាលស្រុកអូររាំងឪ តែម្ដង។

## ២-អំពីសេចក្ដីសម្រេចរបស់សាលាដំបូង

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំរបស់ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី លេខ ១៦៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ ដែលបានសម្រេចសេចក្ដីដូចខាងក្រោម៖

១/ មិនព្រមដោះលែងឱ្យនៅក្រៅឃុំ លើជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី ភេទប្រុស អាយុ ១៦ឆ្នាំ (ដែលសាវតាជាតិដូចខាងលើ) នេះឡើយ។

២/-បន្តអនុវត្តឃុំខ្លួនជនត្រូវចោទខាងលើតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៨៩ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ។

-បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់លោក [redacted] រ៉ាតិសិដ្ឋ ជាមេធាវីការពារក្ដីសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី បានប្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៦៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ។

-បានឃើញ របាយការណ៍ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមរបាយការណ៍សាលា ឧទ្ធរណ៍ត្បូងឃ្មុំ។

-បានឃើញ សេចក្ដីសន្និដ្ឋានចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ របស់តំណាងមហាអយ្យការសាលា ឧទ្ធរណ៍ត្បូងឃ្មុំ។

## ៣. កិច្ចពិភាក្សាដេញដោល

-ប្រធានក្រុមប្រឹក្សាបានអានរបាយការណ៍រឿង

-តំណាងមហាអយ្យការ បានធ្វើសេចក្ដីសន្និដ្ឋាន

-ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា បានឆ្លើយថា៖ ខ្លួនប្ដឹងឧទ្ធរណ៍ដោយសារមិនសុខចិត្តលើការសម្រេចរបស់សាលាដំបូងដោយខ្លួនស្នើសុំនៅក្រៅឃុំខ្លួន។ ឪពុករបស់ខ្លួនស្លាប់ និងម្ដាយនៅរស់នៅខេត្តព្រះសីហនុ ម្ដាយរបស់ខ្លួនបានគេចោលខ្លួនតាំងតែពីតូច ខ្លួនរស់នៅជាមួយយាយតែគាត់បានស្លាប់រយៈពេលចំនួន ២ឆ្នាំ មកហើយ បន្ទាប់ពីយាយរបស់ខ្លួនស្លាប់ខ្លួនរស់នៅពីនាក់ប្អូនអាយុ ៨ឆ្នាំ ខ្លួនមានផ្ទះស្នាក់នៅភូមិថ្មីសែនជ័យ ឃុំទូលសូភី ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ខ្លួនរស់នៅកាលពីឆ្នាំ២០១៨ ជាផ្ទះរបស់យាយ បន្ទាប់ពីយាយរបស់ខ្លួនស្លាប់គឺខ្លួនជារស់ទីនោះ ខ្លួនអត់មានដីស្រែចំការនោះទេ។ ខ្លួនធ្វើការលើជ័របានប្រាក់១ ថ្ងៃចំនួន ៣០,០០០ រៀល បានជាខ្លួនលួចទូរស័ព្ទគេ ព្រោះខ្លួនអត់មានទូរស័ព្ទសម្រាប់ប្រើ ខ្លួនចង់បានទូរស័ព្ទសម្រាប់មកប្រើ មើលរឿង នៅផ្ទះអត់មានទូរទស្សន៍នោះទេ។ សម្រាប់ប្រាក់ ១,០០០,០០០ រៀល ដែលឈ្មោះ [redacted] សារិន ថាខ្លួនយកនោះ ខ្លួនអត់បានយកនោះទេ។ ខ្លួនអត់ដឹងថាប្រាក់នោះទៅណានោះទេ ចំណែកទូរស័ព្ទគេដាក់នៅលើគ្រែ នៅក្នុងបន្ទប់ តែគេបើកទ្វារចំហរ ផ្ទះនោះខ្លួនអត់ដែលបានចូលពីមុននោះទេ ផ្ទះនៅក្នុងចំការកៅស៊ូ ខ្លួនស្គាល់ម្ចាស់ផ្ទះ។ ក្រៅពីមុខរបរជៀសជ័រកៅស៊ូ ខ្លួនស៊ីឈ្នួលដាំដុះ ក្រោយខ្លួនជាប់ពន្ធនាគារខ្លួនអត់ដឹងប្អូនរបស់ខ្លួនរស់នៅជាមួយអ្នកណានោះទេ។ ប្រសិនបើតុលាការឱ្យខ្លួននៅក្រៅឃុំ ហើយមានការងារធ្វើ មានហូបគ្រប់គ្រាន់ ខ្លួនព្រមទៅរស់នៅ ដោយខ្លួនចង់មានការងារធ្វើ នឹងអត់ចង់ជាប់ពន្ធនាគារនោះទេ។ ការ

ជាប់ពន្ធនាគារអត់ស្រួលដូចការធ្វើការនៅខាងក្រៅ។ ខ្លួនជាប់ពន្ធនាគាររយៈពេលចំនួន ៣ ខែជាងហើយ អត់មានបានដំណឹងពីប្អូនរបស់ខ្លួននោះទេ ម្ដាយរបស់ខ្លួនអត់បានដឹងថាខ្លួនជាប់ពន្ធនាគារនោះទេ។ ខ្លួនធ្លាប់បាននៅក្រៅឃុំខ្លួនទៅរស់នៅភូមិថ្មីសែនជ័យ ផ្ទះរបស់យាយ ពេលចេញទៅខ្លួនរកការងារធ្វើ។ កន្លងមកខ្លួនធ្លាប់លួចចេកគេបានម្ដង និងលួចមាន់គេ។ ប្រសិនបើតុលាការឱ្យខ្លួននៅក្រៅឃុំ ខ្លួនសុខចិត្តឱ្យភ្នាក់ងារសង្គមកិច្ចតាមដាន និងត្រួតពិនិត្យខ្លួន។ ខ្លួនឈប់ប្រព្រឹត្តបទល្មើសទៀតហើយ ខ្លួននឹងកែប្រែខ្លួនឱ្យក្លាយទៅជាពលរដ្ឋល្អនៅក្នុងសង្គម។

-អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិន បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនសុំរក្សាចម្លើយរបស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ទុកជាបានការដដែលដោយមិនមានការកែប្រែនោះទេ។ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ ម៉ោងប្រហែល ៤ ល្ងាច ខ្លួនកំពុងធ្វើការនៅក្រុមហ៊ុនចំការកៅស៊ូអានម៉ារ៉ានីពាមជាំង ស្ថិតនៅភូមិ៤៤ ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ដោយពេលនោះប្រពន្ធរបស់ខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា មានចោរចូលផ្ទះលួចយកទូរស័ព្ទដៃចំនួន ០១គ្រឿង, បាត់កូនជ្រូកសន្សំលុយចំនួន ០១ និងបាត់ទឹកផ្លែឈើមួយចំនួន។ ក្រោយពីទទួលដំណឹងហើយ ខ្លួនក៏បានឆែក GPS ក្នុងទូរស័ព្ទដៃរបស់ខ្លួន ហើយក៏បានដឹងពីទីតាំងថាអ្នកលួចនៅឯណា និងប្ដឹងសមត្ថកិច្ចឱ្យចុះទៅចាប់ឃាត់ខ្លួនអ្នកលួចនោះតែម្ដងទៅ។ ក្រោយពីសមត្ថកិច្ចចាប់ឃាត់ខ្លួនអ្នកលួចនោះហើយ ទើបខ្លួនដឹងថា អ្នកលួចនោះ គឺឈ្មោះ [redacted] ប៊ុនថា ហៅ នី ភេទប្រុស អាយុ ១៦ឆ្នាំ រស់នៅក្នុងភូមិថ្មីសែនជ័យ ឃុំទួលសុភី ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ក្រោយសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] ប៊ុនថា ហៅ នី ហើយសមត្ថកិច្ចបានដកហូតយកទូរស័ព្ទម៉ាក អាយហ្វូនស៊ិច ចំនួន ០១គ្រឿងមកប្រគល់ឱ្យខ្លួនវិញ តែចំពោះលុយក្នុងកូនជ្រូក និងគ្រឿងកំប៉ុងគឺមិនបានប្រគល់ឱ្យខ្លួនវិញនោះទេ។ ចំពោះលុយក្នុងកូនជ្រូកខ្លួន មិនដឹងថាមានចំនួនប៉ុន្មាននោះទេ ដោយគិតថាលុយនោះប្រហែល ១,០០០,០០០ (មួយលាន) រៀល។ ខ្លួនស្គាល់ពុំសូវច្បាស់នោះទេ ដោយខ្លួនស្គាល់ត្រឹមថា វាជាក្មេងដែលចូលចិត្តដើរលួចទ្រព្យសម្បត្តិគេយ៉ាងសកម្ម ហើយអ្នកស្រុកភូមិក៏មានការត្រេកអរផងដែរ ចំពោះការចាប់ខ្លួនឈ្មោះនេះ។ តាមពិតទៅខ្លួនក៏ធ្លាប់ឧបត្ថម្ភដល់ឈ្មោះ [redacted] ប៊ុនថា ហៅ នី នេះ នូវកង់ចំនួន ០១ គ្រឿង និងគ្រឿងបរិភោគមួយចំនួន តែកង់ដែលខ្លួនឱ្យទៅវានោះ គឺវាជិះទៅលួចទ្រព្យគេ ក៏ត្រូវគេយកកង់នោះបាត់ទៅ។ ចំពោះប្អូនរបស់ឈ្មោះ វី ប៊ុនថា នេះគឺសព្វថ្ងៃនៅជាមួយម្ដាយ មិនមែនដូចការនិយាយរបស់ឈ្មោះ [redacted] ប៊ុនថា នោះទេ។ នៅក្នុងសំណុំរឿងនេះ ខ្លួនមិនប្ដឹងទាមទារសំណងអ្វីនោះទេ ដោយខ្លួនទុកឱ្យតុលាការសម្រេចផ្ដន្ទាទោសជនល្មើសតាមច្បាប់ចុះ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ម៉ារ៉ាត បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនសុំរក្សាចម្លើយរបស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ទុកជាបានការដដែលដោយមិនមានការកែប្រែនោះទេ។ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ ម៉ោងប្រហែល ៥ ល្ងាច ខ្លួនបានត្រឡប់មកពីកន្លែងលក់ដូរវិញ ពេលនោះកូនរបស់ខ្លួនក៏បានប្រាប់ខ្លួនថាឈ្មោះ [redacted] ប៊ុនថា ហៅ នី ភេទប្រុស អាយុប្រហែល ១៦ឆ្នាំ នៅភូមិថ្មីសែនជ័យ ឃុំទួលសុភី ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ដោយនៅឆ្ងាយពីផ្ទះខ្លួនដែរ បានចូលមករើយកភេជ្ជៈ (គ្រឿងកំប៉ុង) មួយចំនួន លុយសន្សំរបស់កូនខ្លួនដែលបានដាក់ក្នុងកូនជ្រូក ចំនួនប្រហែល ១,០០០,០០០ រៀល និងយកទូរស័ព្ទរបស់ខ្លួន ម៉ាក Iphone 6plus ចំនួន ០១គ្រឿង តែពេលនោះខ្លួនមិនបាននៅផ្ទះនោះទេ គឺកូនរបស់ខ្លួនជាអ្នកនៅចាំផ្ទះ ដោយកូនរបស់ខ្លួន បើកចំហរទ្វារក្រោយផ្ទះចោល ហើយភ្លាមនោះខ្លួនក៏បានខលទៅប្រាប់ប្ដីរបស់ខ្លួនថា "បងមានចោរចូលលួច ទូរស័ព្ទដៃ និងរើរបស់របរនៅក្នុងផ្ទះយើង"។ ខ្លួនមិនសូវស្គាល់ឈ្មោះ [redacted] ប៊ុនថា ច្បាស់ប៉ុន្មាននោះទេ។ ឈ្មោះ [redacted] ប៊ុនថា ជាមនុស្សចូលចិត្តដើរយករបស់គេ ស្ទើរាល់ថ្ងៃ។ ខ្លួនមិនឃើញឈ្មោះ [redacted] ប៊ុនថា ចូលមកលួចដោយផ្ទាល់ភ្នែកនោះទេ។ ខ្លួនបានដឹងតែប៉ុណ្ណឹង ចំពោះរឿងរ៉ាវផ្សេងទៀត ខ្លួនមិនដឹងនោះទេ។

-លោក [redacted] សាលី ជាភ្នាក់សង្គមកិច្ចខេត្តត្បូងឃ្មុំ បានឆ្លើយថា៖ មន្ទីរសង្គមកិច្ចមានទីតាំងស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ ប្រសិនឱ្យឈ្មោះ [redacted] ប៊ុនថា នៅក្រៅឃុំខាងសង្គមកិច្ចអាចធ្វើការតាមដាននូវវឌ្ឍនភាពរបស់បានពួកគាត់បានល្អប្រសើរផង ដោយសារតែខេត្តត្បូងឃ្មុំ អត់មានមណ្ឌល ក៏ប៉ុន្តែខ្លួនធ្វើគ្រប់គ្រងដោយចុះរបស់ពួកគាត់ចូលទៅប្រព័ន្ធ និងធ្វើផែនការសម្រាប់ជួយដល់ពួកគាត់។ ការជួយទាំងដល់ពួកគាត់សិក្សាទៅលើជីវភាពគ្រួសាររបស់ពួកគាត់ និងផែនការជាមួយអាជ្ញាធរ ដើម្បីឱ្យពួកគាត់ទទួលខុសត្រូវលើបញ្ហាទាំងអស់នឹងដែរ ជាពិសេសសាច់ញាតិណាខ្លះដែលបានប្ដេជ្ញា



Scanned with CamScanner

ជួយដល់ឈ្មោះ [redacted] ប៊ុនថា គឺមានម្ដាយមីងដែលមានប្ដីជាអ្នករត់ឡាន និងឈ្មោះ [redacted] ប៊ុនថា អាចទៅរស់នៅជាមួយបាន ម្ដាយមីងនោះបាន ព្រោះឈ្មោះនេះ អាចទៅរត់ឡានជាមួយពូរបស់គាត់បាន។ ភ្នាក់ងារសង្គមកិច្ចធ្វើការចុះតាមដាន រាល់ ១ខែ ម្ដង ឬ ៣ខែម្ដង អាស្រ័យទៅលើអនីតិជនដោយផ្អែកទៅលើវឌ្ឍនភាពរបស់អនីតិជន។

-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ផ្អែកតាមការពិភាក្សាផេញដោលក្នុងអង្គសវនាការនេះ ឃើញថាលោក [redacted] រ៉ាពិសិដ្ឋ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា បានស្នើសុំឱ្យជនត្រូវចោទនៅក្រៅឃុំ តែត្រូវថ្លែងតាមពិភាក្សាផេញដោលនេះ ឃើញថា ជនត្រូវចោទអាចមានការលំបាកប្រសិនបើពុំមានអាណាព្យាបាល ទទួលខុសត្រូវនោះទេ។ ពីព្រោះថាប្រសិនបើគ្មានអ្នកឧបត្ថម្ភ ទទួលខុសត្រូវ មើលថែអនីតិជននោះ និងខ្វះនូវអាហារ ហូប ប្រសិនបើឈ្មោះ [redacted] ប៊ុនថា រកការងារធ្វើមិនបាននោះ និងប្រឈមនឹងការប្រព្រឹត្តបទល្មើសតទៅទៀត នោះធ្វើជន ត្រូវចោទនៅតែប្រព្រឹត្តល្មើសដដែល។ ប្រសិនបើមានអ្នកទទួលខុសត្រូវច្បាស់លាស់ធានាបាននូវជននេះអាចនឹងមាន ការកែប្រែទៅជាពលរដ្ឋល្អនៅក្នុងសង្គម។ តំណាងមហាអយ្យការទុកសិទ្ធិឱ្យក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់។

-លោក [redacted] រ៉ាពិសិដ្ឋ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ខ្លួន សុំឱ្យដោះលែងកូនក្ដីខ្លួនឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន បានទៅរស់នៅក្នុងសង្គមជាធម្មតាវិញ ហើយចៅក្រមស៊ើប សួរបានបដិសេធ ដោយបានលើកយកមូលហេតុ និងសំអាងហេតុ ដែលដូចនៅក្នុងដីកាសម្រេច៖

១-មូលហេតុនៃការឃុំខ្លួននៅក្នុងដីកាសម្រេចលេខ ១៦៧០ ព្រទ.១ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៣ នៅតែមាន ភាពចាំបាច់ ដើម្បីបន្តការស៊ើបសួរ។ ប៉ុន្តែខ្លួនពិនិត្យសំណុំរឿងទៅឃើញថា សំអាងហេតុនេះអត់ត្រឹមត្រូវទេ ដោយហេតុ ថាកូនក្ដីខ្លួនត្រូវបាន ខ្លួនដាក់ពាក្យសុំឱ្យនៅក្រៅឃុំ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ហើយពេលដែលខ្លួនពាក្យសុំនៅ ក្រៅឃុំ រហូតចេញដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ គឺចៅក្រមស៊ើបសួរពុំបានធ្វើកិច្ចណាមួយ ចំពោះកូនក្ដីខ្លួននោះទេ ដូច្នេះឃើញថាដីកាដំណោះស្រាយជាដីកាមួយសម្រាប់បញ្ចប់សំណុំរឿងស៊ើបសួរ អាចលើក លែងចោទប្រកាន់ និងអាចបញ្ជូនរឿងទៅជម្រះ មានន័យកិច្ចស៊ើបសួរត្រូវបានបញ្ចប់ហើយ ហេតុនេះមូលហេតុទី១ ពុំ មានភាពចាំបាច់នោះទេ។

២-តាមពាក្យស្នើសុំឱ្យដោះលែងកូនក្ដីឱ្យនៅក្រៅឃុំបណ្ដោះអាសន្នខាងលើនេះ ពុំមានមូលដ្ឋានគ្រប់គ្រាន់ និង ច្បាស់លាស់ ដើម្បីឱ្យចៅក្រមស៊ើបសួរសម្រេចអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំបានឡើយ។ ការយល់ឃើញកន្លែង នេះគឺ គាត់ពុំបានមើលទៅលើពាក្យសុំនៅក្រៅឃុំរបស់ខ្លួននោះទេ ខ្លួនយោងទៅលើផ្លូវច្បាប់ស្ដីពីយុត្តិធម៌អនីតិជន យោងតាមមាត្រា ៤១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។

៣-តាមយោបល់របស់តំណាងអយ្យការ ទុកសិទ្ធិឱ្យចៅក្រមស៊ើបសួរសម្រេចតាមនីតិវិធីច្បាប់។ តាមយោបល់ របស់តំណាងអយ្យការនេះ ចៅក្រមស៊ើបសួរនឹងសម្រេចទៅតាមនីតិវិធីច្បាប់។ ចំពោះច្បាប់ស្ដីពី យុត្តិធម៌អនីតិជន គឺ ត្រូវតែដោះលែងឱ្យមានសេរីភាព អត់ទុកនៅក្នុងឃុំនោះទេ ព្រោះត្រូវជៀសវាងទទួលបានបទពិសោធន៍ពីកន្លែងឃុំខ្លួន ជៀសវាងការប្រព្រឹត្តបទល្មើសថែមថ្មីទៀតដែលទទួលបទពិសោធន៍មក។

៤-ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី ត្រូវបានចោទប្រកាន់ក្នុងបទមជ្ឈិម ក៏ប៉ុន្តែតាមកស្តុតាងដែលមាននៅក្នុង សំណុំរឿង តាមរបាយការណ៍របស់សមត្ថកិច្ច តាមចម្លើយរបស់ដើមបណ្ដឹង និងសាក្សី ឃើញថាជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី បានប្រព្រឹត្តអំពើលួចយ៉ាងសកម្មក្នុងមូលដ្ឋានដែលជននេះរស់នៅ ហើយមិនមានវិធានការត្រួតពិនិត្យ តាមផ្លូវតុលាការណាមួយមានលក្ខណៈតឹងរឹង និងអាចធានាឱ្យមានការបំពេញកិច្ចស៊ើបសួរប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់លើបទល្មើសមជ្ឈិម នេះបានឡើយ និងបារម្ភចំពោះជនត្រូវចោទពេលនៅក្រៅឃុំអាច បន្តប្រព្រឹត្តសកម្មភាពល្មើសច្បាប់ថែមទៀត។ ដូចនេះ ការឃុំបណ្ដោះអាសន្ន នៅតែមធ្យោបាយតែមួយគត់ ដើម្បី សម្រេចគោលដៅនៃកិច្ចស៊ើបសួរ។ ចំពោះការយល់ក៏ពុំមែនការយល់ឃើញត្រឹមត្រូវនោះដែរ ម្យ៉ាងវិញទៀតពាក់ព័ន្ធ រយៈពេលនៃការឃុំខ្លួន ជាគោលការណ៍គឺជនត្រូវចោទត្រូវតែមានសេរីភាព តាមច្បាប់ដែលមានចែងក្នុងមាត្រា ២០៣ ហើយរយៈពេលនៃការឃុំខ្លួនដែលមានចែងក្នុងមាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងអនីតិជនគឺ មិនឱ្យ លើសពីពាក់កណ្ដាលនៃអប្បបរមាឡើយ។ ដូច្នេះការប្រព្រឹត្តរបស់ឈ្មោះ [redacted] ប៊ុនថា ត្រូវចោទប្រកាន់ពីបទ លួច ត្រូវផ្ទុយ



Scanned with CamScanner

ទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ហើយកម្រិតទោសអប្បបរមា ចំនួន ៦ខែ ពាក់កណ្ដាល ៣ខែ ចំណែកការជាប់ឃុំកូនក្តីខ្លួនមកដល់ថ្ងៃនេះ គឺ ៣ខែ ៩ថ្ងៃ ឃើញថាឃុំខ្លួននេះលើសច្បាប់កំណត់ហើយ ផ្អែកតាមច្បាប់តុលាការត្រូវតែឱ្យកូនក្តីខ្លួននៅក្រៅឃុំ។ ក្នុងនោះដែរទោះបីជាកូនក្តីខ្លួននៅក្រៅឃុំ ក៏តាមច្បាប់តុលាការអាចដាក់តាមការពិនិត្យតាមរយៈសង្គមកិច្ច តាមដានរយៈពេល ៦ខែ ដែលតុលាការអនុញ្ញាតឱ្យនៅក្រៅឃុំ។ ករណីដែលកូនក្តីខ្លួននៅក្រៅឃុំអាចទៅធ្វើការជាមួយគ្រឹះស្ថានណាមួយ ហើយក្រោមពិនិត្យរបស់ភ្នាក់ងារសង្គមកិច្ច ដែលមានការចូលរួមពីអាជ្ញាធរភូមិឃុំ និងម្ចាស់គ្រឹះស្ថាននោះ សហការជាមួយភ្នាក់ងារសង្គមកិច្ច ដើម្បីឱ្យពត៌មានមកសង្គមកិច្ច សង្គមកិច្ចធ្វើរបាយការណ៍ប៉ានប្រមាណជូនតុលាការនៅក្នុងរឿងអង្គសេចក្តី។ នៅក្នុងរឿងនេះកូនក្តីខ្លួនអត់មានអាណាព្យាបាលនៅជាឈ្មោះ [redacted] ប៊ុនថា នោះទេ។ ហេតុដូច្នេះសុំឱ្យតុលាការមេត្តាពិនិត្យ និងសម្រេចឱ្យកូនក្តីខ្លួននៅក្រៅឃុំទៅតាមផ្លូវច្បាប់ដោយក្តីអនុគ្រោះ។

-ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា បានសំណូមពរចុងក្រោយថា សូមតុលាការដោះលែងខ្លួនឱ្យបាននៅក្រៅឃុំវិញផង។

- ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
- ក្រោយពីបានស្តាប់ចម្លើយភ្នាក់ងារសង្គមកិច្ច
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនត្រូវចោទ
- ក្រោយពីបានស្តាប់សូមណូមពរចុងក្រោយរបស់ជនត្រូវចោទ
- ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## ៤. សំអាងហេតុ

៤-១.ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់លោក [redacted] វ៉ាពិសិដ្ឋ ជាមេធាវីការពារក្តីសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី បានប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៦៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ

បណ្តឹងឧទ្ធរណ៍នេះ ធ្វើឡើងក្នុងកំណត់ច្បាប់ សភាស៊ើបសួរសាលាឧទ្ធរណ៍ ទទួលជំនុំជម្រះបាន យោងតាមមាត្រា ២៦៧ និងមាត្រា ២៧០ និងមាត្រា ២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-២.ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី (មានសាវតាជាតិដូចខាងលើ) ត្រូវបានចោទប្រកាន់ពីបទ៖ លួចប្រព្រឹត្តនៅចំណុចភូមិ៤៤ ឃុំព្រះធាតុ ស្រុកអូររាំងឪខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ដែលជាបទល្មើសមជ្ឈិម។

៤-៣.ចៅក្រមស៊ើបសួរសម្រេចមិនព្រមដោះលែងឱ្យជនត្រូវចោទ [redacted] ប៊ុនថា ហៅ នី នៅក្រៅឃុំ ដោយសំអាងថា៖

-មូលហេតុនៃការឃុំខ្លួននៅក្នុងដីកាសម្រេចលេខ ១៦៧០ ព្រទ.១ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៣ នៅតែមានភាពចាំបាច់ ដើម្បីបន្តការស៊ើបសួរ។

-តាមពាក្យស្នើសុំឱ្យដោះលែងកូនក្តីឱ្យនៅក្រៅឃុំបណ្តោះអាសន្នខាងលើនេះ ពុំមានមូលដ្ឋានគ្រប់គ្រាន់ និងច្បាស់លាស់ ដើម្បីឱ្យចៅក្រមស៊ើបសួរសម្រេចអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំបានឡើយ។

-តាមយោបល់របស់តំណាងអយ្យការ ទុកសិទ្ធិឱ្យចៅក្រមស៊ើបសួរសម្រេចតាមនីតិវិធីច្បាប់។ តាមយោបល់របស់តំណាងអយ្យការនេះ ចៅក្រមស៊ើបសួរនឹងសម្រេចទៅតាមនីតិវិធីច្បាប់។

-ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី ត្រូវបានចោទប្រកាន់ក្នុងបទមជ្ឈិម ក៏ប៉ុន្តែតាមភស្តុតាងដែលមាននៅក្នុងសំណុំរឿង តាមរបាយការណ៍របស់សមត្ថកិច្ច តាមចម្លើយរបស់ដើមបណ្តឹង និងសាក្សី ឃើញថាជនត្រូវចោទឈ្មោះ [redacted]



Scanned with CamScanner

ប៊ុនថា ហៅ នី បានប្រព្រឹត្តអំពើលួចយ៉ាងសកម្មក្នុងមូលដ្ឋានដែលជននេះរស់នៅ ហើយមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយមានលក្ខណៈតឹងរ៉ឹង និងអាចធានាឱ្យមានការបំពេញកិច្ចស៊ើបសួរប្រកបដោយប្រសិទ្ធភាពចំពោះស្ថានភាពតម្រូវទាំងអស់លើបទល្មើសមជ្ឈិម នេះបានឡើយ និងបារម្ភចំពោះជនត្រូវចោទពេលនៅក្រៅឃុំអាចបន្តប្រព្រឹត្តសកម្មភាពល្មើសច្បាប់ថែមទៀត។ ដូចនេះ ការឃុំបណ្ដោះអាសន្ន នៅតែមធ្យោបាយតែមួយគត់ ដើម្បីសម្រេចគោលដៅនៃកិច្ចស៊ើបសួរ។

៤-៤.សំអាងហេតុរបស់ចៅក្រមស៊ើបសួរ ដូចបានចង្អុលបង្ហាញខាងលើក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យឃើញថា៖ ពុំមានភាពចាំបាច់ខ្លាំងសម្រាប់ការឃុំខ្លួនឡើយ ដោយហេតុថាជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ជាអនីតិជនដែលកំពុងស្ថិតក្នុងវ័យទទួលការអប់រំ និងបណ្ដុះបណ្ដាល។ ប៉ុន្តែដោយហេតុថា ជនត្រូវចោទមានការយល់ដឹងមានកម្រិតទាប ហើយមិនទទួលបានការមើលថែដឹកដល់ពីឪពុក ម្ដាយ និងសេពគប់ជាមួយមនុស្សមិនល្អ ព្រមទាំងជីវភាពខ្វះខាតទៀតនោះ ធ្វើឱ្យជនត្រូវចោទឈានដល់ការប្រព្រឹត្តអំពើជាបទល្មើសទាំងវ័យក្មេងជាអនីតិជន។

៤-៥.យោងតាមរបាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខមាភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់ នឹងច្បាប់ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ របស់ភ្នាក់ងារសង្គមកិច្ច ឃើញថា មានភាពច្បាស់លាស់ ហើយម្យ៉ាងទៀត បើពិនិត្យទៅលើប្រវត្តិ នៃផ្ដន្ទាទោសដោយតុលាការវិញ ឃើញថាជនត្រូវចោទមិនធ្លាប់ត្រូវបានតុលាការផ្ដន្ទាទោលពីបទល្មើសណាមួយនោះទេ គប្បីសាលាឧទ្ធរណ៍លើកយកមាត្រា ៣៩,មាត្រា ៤០ និង ៤១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន មកពិចារណា។

៤-៦.ការស៊ើបសួរមានលក្ខណៈជឿនលឿន បើសការស៊ើបសួរអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្ន នឹងមិនប៉ះពាល់ដល់នីតិវិធីនៃការស៊ើបសួរឡើយ យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ដូច្នេះ ដើម្បីធានាដល់ដំណើរការនីតិវិធី របស់តុលាការ ជំនុំជម្រះនាពេលអនាគតឱ្យបានល្អ សការស៊ើបសួរគប្បីពិចារណាដាក់ជនត្រូវចោទ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយពិចារណាតាមមាត្រា២២៣ និង មាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ម្យ៉ាងទៀត ជនត្រូវចោទមានទីលំនៅច្បាស់លាស់ គឺស្ថិតនៅភូមិឡ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

៤-៧.ផ្អែកតាមសំអាងហេតុដូចខាងលើ សាលាឧទ្ធរណ៍ពិចារណាឃើញថា គួរគប្បីបដិសេធដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំលេខ: ១៦៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តត្បូងឃ្មុំ ចោលជាអសាបង់ និងសម្រេចអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី នៅក្រៅជាបណ្ដោះអាសន្ន ប្រសិនបើជននេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងនោះទេ។

៤-៨.តាមសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទបានធ្វើសេចក្ដីសន្និដ្ឋានថា បានស្នើសុំឱ្យក្រុមប្រឹក្សាពិនិត្យ និងសម្រេចដោយឈរលើច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឃើញថាការស្នើសុំនេះមានលក្ខណៈសមស្របតាមច្បាប់ ដែលអាចឱ្យក្រុមប្រឹក្សាធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្ដី។

## ៥. ហេតុដូច្នេះ សម្រេច

៥-១.ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់លោក [redacted] រ៉ាតិសិដ្ឋ ជាមេធាវីការពារក្ដីសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី ដែលបានប្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៦៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាត្រឹមត្រូវតាមទម្រង់ នឹង គតិច្បាប់។

៥-២.បដិសេធដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៦៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ ចោលជាអសាបង់។

៥-៣.អនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី ភេទប្រុស អាយុ ១៦ឆ្នាំ (មានសាវតាជាតិខាងលើ) ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ លួច ប្រព្រឹត្តនៅចំណុចភូមិ៤៤ ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦



Scanned with CamScanner

នៃក្រមព្រហ្មទណ្ឌ ឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន។

៥-៤.បង្គាប់ឱ្យប្រធានពន្ធនាគារខេត្តត្បូងឃ្មុំ ធ្វើការដោះលែង ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី ចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួនជាបន្ទាន់ ប្រសិនបើឈ្មោះខាងលើនេះមិនត្រូវបានជាប់ឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀត។

៥-៥.សម្រេចដាក់ជនត្រូវចោទឈ្មោះ [redacted] ប៊ុនថា ហៅ នី ភេទប្រុស អាយុ ១៦ឆ្នាំ (មានសាវតាជាតិខាងលើ) ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយអនុវត្តនូវកាតព្វកិច្ចមួយចំនួន ដូចខាងក្រោម៖

-ប្រគល់អនីតិជនឈ្មោះ [redacted] ប៊ុនថា ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តត្បូងឃ្មុំ ទទួល និងថែទាំអនីតិជន។

-មិនឱ្យអនីតិជនចេញដើរហួសម៉ោង ២០ និង ០០នាទី។

៥-៦.សាលដីកានេះត្រូវបានពិភាក្សាផ្ដាច់ដោល នៅថ្ងៃចន្ទ ៧ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ និងប្រកាសជាអសាធារណៈនៅថ្ងៃអង្គារ ៨ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣។

បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

| ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ក្រឡាបញ្ជី |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៨ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ត្បូងឃ្មុំ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner